# តួនាទីរបស់តុលាការកម្ពុជាក្នុងករណីនយោបាយ

ករណីសិក្សាមួយពីខេត្តតាកែវ

ខែកក្កដា ឆ្នាំ២០១០




*លាង សុខជឿន ត្រូវបាននាំខ្លួនចូលតុលាការខេត្តតាកែវ បន្ទាប់ពីត្រូវបានឃុំខ្លួនអស់រយៈពេល ៣៣ ម៉ោង*
*នៅក្នុងមន្ទីរឃុំឃាំងរបស់នគរបាល ដោយផ្ដាច់ទំនាក់ទំនង*

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ
LICADHO
CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

# ប្រវត្តិករណី

នៅថ្ងៃសៅរ៍ ទី២៩ ខែឧសភា ឆ្នាំ២០១០ វេលាម៉ោង ៦ និង១៥នាទីព្រឹក លោកលាង សុខជឿន ដែលជាបុគ្គលិកអង្គការលីកាដូ ត្រូវបានចាប់ខ្លួននៅផ្ទះរបស់គាត់ក្នុងខណ្ឌសែនសុខ រាជធានីភ្នំពេញ ដោយមន្ត្រីនគរបាលមកពីនាយកដ្ឋានសន្តិសុខផ្ទៃក្នុងនៃក្រសួងមហាផ្ទៃ។ ក្រោយពីត្រូវបានចាប់ខ្លួន លោក សុខជឿន ត្រូវបានបញ្ជូនទៅអគ្គនាយកដ្ឋាននគរបាលជាតិនៃរាជធានីភ្នំពេញ ដែលនៅទីនោះ គេបានឃុំខ្លួនគាត់អស់រយៈពេល ៣៣ ម៉ោង ដោយត្រូវផ្តាច់ការទាក់ទង ទោះបីជាគ្រួសារ និងមេធាវីរបស់គាត់បានស្នើសុំជួបជាច្រើនដងក៏ដោយ។

កម្ពុជា គឺជារដ្ឋភាគីមួយ នៃកត្តិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ[១] មាត្រា ៩ (១) នៃកត្តិកាសញ្ញានេះ បានចែងដូចខាងក្រោម :

*"ជនគ្រប់រូបមានសិទ្ធិមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។ គ្មានជនណាម្នាក់ត្រូវចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្តបានឡើយ។ គ្មានជនណាម្នាក់ ត្រូវដកហូតសេរីភាពនេះបានឡើយ លើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់"*។

គណៈកម្មាធិការសិទ្ធិមនុស្ស ជាតួអង្គសន្ធិសញ្ញា ដែលមានភារកិច្ចក្នុងការត្រួតពិនិត្យរដ្ឋភាគីនានាក្នុងការ"អនុវត្តន៏កត្តិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយបានបញ្ជាក់ថា ការដកហូតសេរីភាពក្នុងគ្រប់ករណីទាំងអស់ត្រូវតែអនុវត្តដោយអនុលោមតាមច្បាប់នៅក្នុងប្រទេសនោះ (គោលការណ៍នៃសេរីភាព)។ អ្វីដែលសំខាន់ជាងនេះទៅទៀតគឺគណៈកម្មាធិការបានកំណត់ថា ការដកហូតសេរីភាព ***មិនត្រូវធ្វើឡើងតាមអំពើចិត្តទេ*** ជាការបញ្ជាក់ច្បាស់ថា "*ការដកហូតតាមអំពើចិត្ត មិនត្រូវធ្វើដោយខុសច្បាប់ឡើយ ប៉ុន្តែគួរត្រូវបានបកស្រាយឱ្យបានទូលំទូលាយដោយមានបញ្ចូលនូវធាតុទាំងឡាយដូចជា ភាពមិនត្រឹមត្រូវ អយុត្តិធម៌ កង្វះការព្យាករណ៍ទុកជាមុន និងការអនុវត្តន៏ស្របច្បាប់*"។[២]

ការចាប់លោកលាង សុខជឿន និងការញូនទៅឃុំខ្លួនដោយតុលាការកម្ពុជា បង្ហាញនូវសញ្ញានានាអំពីភាពមិនសមរម្យ អយុត្តិធម៌ ខ្វះការព្យាករណ៏ទុកជាមុន និងមិនស្របតាមអ្វីដែលគណកម្មាធិការសិទ្ធិមនុស្សបានលើកឡើង។ ការរំលោភបំពានទាំងនេះ គឺជាលក្ខណៈនៃប្រព័ន្ធនយោបាយ ដែលបរាជ័យក្នុងការអនុវត្តន៏ច្បាប់ជាមូលដ្ឋានពិតៗ។

---

[១] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា " ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សនានាដែលមានចែងនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងគ្រប់សន្ធិសញ្ញា និងអនុសញ្ញាទាំងអស់ដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ"។

[២] សេចក្តីជូនដំណឹងលេខ ៤៥៨/១៩៩១ A.W. Mukong v. Cameroon in UN doc. GOAR, A/49/40 (vol 11), P. 181, para 9.8

# ការស៊ើបអង្កេតបឋម និង ដំណើរការបញ្ជូនរឿងអោយស៊ើបសួរប្រឆាំងលើលោក លាង សុខជឿន

នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១០ នគរបាលខេត្តតាកែវ បានបញ្ជូនរបាយការណ៍មួយច្បាប់ទៅការិយាល័យតំណាងអយ្យការអមតុលាការខេត្តតាកែវ ស្នើសុំបើកការស៊ើបអង្កេតមួយ[៣] ដែលពាក់ព័ន្ធជាមួយនឹងការចោទប្រកាន់ពីបទចែកផ្សាយខិតប័ណ្ណ ៤ដង នៅខេត្តតាកែវ ដែលកើតឡើងក្នុងចន្លោះពីថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០០៩ និងថ្ងៃទី២១ ខែមករា ឆ្នាំ២០១០។ ខិតប័ណ្ណទាំងនោះមានចេតនា *"ជេរប្រមាថថ្នាក់ដឹកនាំប្រទេស និងសម្តេចព្រះមហាវីរៈក្សត្រ"*។ ក្នុងករណីនេះ នគរបាលខេត្តតាកែវក៏បានជូនដំណឹងទៅនាយកដ្ឋានសន្តិសុខផ្ទៃក្នុងនៃក្រសួងមហាផ្ទៃអំពីឧប្បត្តិហេតុទាំងនោះដែរ ។

នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១០ ជាការបន្ថែមទៅលើរបាយការណ៍ដើមរបស់នគរបាលតំណាងអយ្យការអមតុលាការខេត្តតាកែវ លោកមាស សុភ័ក្ត បានបើកការស៊ើបអង្កេតជាផ្លូវការព្រមទាំងណែនាំដល់នគរបាលខេត្ត *"ឱ្យធ្វើការស្រាវជ្រាវរកភស្តុតាង និងបញ្ជូនរបាយការណ៍ស៊ើបអង្កេតទៅការិយាល័យរបស់គាត់"*។

មួយថ្ងៃក្រោយមក ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ នគរបាលខេត្តតាកែវក៏បានបញ្ជូនរបាយការណ៍ស៊ើបអង្កេតរបស់ខ្លួនទៅការិយាល័យអយ្យការអមតុលាការ ដែលនៅក្នុងរបាយការណ៍នោះមាន ៣ ផ្នែកធំៗគឺៈ (១)របាយការណ៍ស្តីពីការស៊ើបអង្កេតរបស់នគរបាលនៅកន្លែងចែកផ្សាយខិតប័ណ្ណ (២)ចម្លើយសាក្សី ៤ នាក់ (៣)លទ្ធផលនៃការថតសម្លេងទូរស័ព្ទ ។ ជាខ្លឹមសាររបាយការណ៍នគរបាលអំពីលទ្ធផលនៃការស្រាវជ្រាវនៅទីកន្លែងកើតហេតុ គ្មានអ្វីក្រៅពីទីតាំង និងចំនួនខិតប័ណ្ណដែលបានរកឃើញឡើយ ហើយតួនាទីរបស់ "សាក្សី" (ឬ បណ្តាញផ្តល់ព័ត៌មានរបស់នគរបាល) គឺគ្រាន់តែបានបញ្ជាក់អំពីការបានដឹងថាឧប្បត្តិហេតុបានកើតឡើងតែប៉ុណ្ណោះ។ ចម្លើយសាក្សីទាំងឡាយនៅក្នុងរបាយ-ការណ៍នគរបាលនោះ ពុំមានបញ្ជាក់នូវចំណុចជាក់លាក់ណាមួយ ដែលបង្ហាញថា លោកលាង សុខជឿន អាចជាប់ពាក់ព័ន្ធនៅក្នុងករណីនោះឡើយ ។

នៅក្នុងផ្នែកដែលសរសេរអំពី ការថតសម្លេង នគរបាលខេត្ត បានផ្តល់ឈ្មោះមនុស្សពីរនាក់ជាអ្វីដែលគេហៅ "អ្នកនៅពីក្រោយខ្នង" ដែលទំនងជាមានការជាប់ពាក់ព័ន្ធជាមួយនឹង "ជនសង្ស័យ" ៤ នាក់ទៀតតាមរយៈទូរស័ព្ទដៃ ។ ជនសង្ស័យម្នាក់ក្នុងចំណោម ៤ នាក់ ក្នុងផ្នែកសរសេរអំពីការថតសម្លេងនៃរបាយការណ៍នគរបាល គឺឈ្មោះ លាង សុខលី

[៣] សូមអានមាត្រា ១២៤ ដែលពាក់ព័ន្ធជាមួយមាត្រា ៤៣-៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ហៅ ជឿន ជនជាតិវៀតណាម ដែលមានអាសយដ្ឋាននៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ហើយ (ព័ត៌មានលំអិតអំពីជននេះប្រហែលជាចម្លងមកពីបញ្ជីឈ្មោះអតិថិជនរបស់ក្រុមហ៊ុនទូរស័ព្ទចល័ត)។

ក្រៅពីភាពខុសគ្នាយ៉ាងខ្លាំងអំពីបញ្ហាឈ្មោះ លាង សុខជឿននេះ នៅមានចំណុចមួយទៀតគឺ គាត់ជាជនជាតិខ្មែររស់នៅខណ្ឌសែនសុខ រាជធានីភ្នំពេញ។ ជាងនេះទៅទៀត ការថតសម្លេងទូរស័ព្ទនោះ ពុំមានចំណុចណាមួយដែលបញ្ជាក់អំពីខ្លឹមសារនៃការសន្ទនាតាមទូរស័ព្ទឡើយ ។ របាយការណ៍ស៊ើបអង្កេតពុំមាននិយាយអ្វីសោះ អំពីរបៀបដែលនគរបាលខេត្តកំណត់បានអត្តសញ្ញាណ "*អ្នកនៅពីក្រោយខ្នងពីរនាក់*" និងអ្វីដែលអាចចោទប្រកាន់ជនទាំងពីរនាក់នោះដោយរកឃើញថា មានការទាក់ទងគ្នាតាមទូរស័ព្ទជាមួយនឹងមនុស្សដែលហៅថា អ្នកនៅពីក្រោយខ្នងនោះឡើយ។

នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១០ អយ្យការអមតុលាការខេត្ត បានចេញដីកាបញ្ជូនរឿងអោយស៊ើបសួរប្រឆាំងលើបុគ្គល ៤ នាក់ក្រោមបទផ្សាយព័ត៌មានមិនពិត (យោងតាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌអន្តរកាល)។ ការចោទនោះ គឺពាក់ព័ន្ធជាមួយនឹងការចែកផ្សាយខិតប័ណ្ណប្រឆាំងរដ្ឋាភិបាលចំនួន ៥៨៧ សន្លឹក កាលពីថ្ងៃទី៤ ខែមករា ឆ្នាំ២០១០ នៅក្រុងដូនកែវ ខេត្តតាកែវ។ ទន្ទឹមនឹងការចេញដីការបញ្ជូនរឿងអោយស៊ើបសួរព្រះរាជអាជ្ញាបានបើកការស៊ើបអង្កេតជាសាធារណៈមួយ ដើម្បីស៊ើបអង្កេតករណីពាក់ព័ន្ធនឹងជនសង្ស័យទាំង ៤ នាក់ [៤]។

បុគ្គលម្នាក់ក្នុងចំណោម ជនសង្ស័យទាំង ៤ នាក់ដែលត្រូវចោទប្រកាន់ គឺជាបុគ្គលម្នាក់ឈ្មោះ លាង សុខលី ហៅ ជឿន ជនជាតិវៀតណាមមានអាសយដ្ឋាននៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដែលបានកំណត់នៅក្នុងការបើកការស៊ើបអង្កេត។ ទោះបីជាមានភាពខុសគ្នា មិនស្របគ្នានៅក្នុងរបាយការណ៍នគរបាលខេត្តតាកែវ និងពុំមានភស្តុតាងគ្រប់គ្រាន់ក៏ដោយក៏អយ្យការអមតុលាការពុំបានធ្វើការស៊ើបការស៊ើបអង្កេតបន្ថែមទៀតដែរ មុននឹងសម្រេចចេញដីការបញ្ជូនរឿងអោយស៊ើបសួរ។ មូលដ្ឋានតែមួយគត់ក្នុងការចោទប្រកាន់របស់គាត់ គឺផ្អែកលើរបាយការណ៍របស់នគរបាលចេញនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ តែប៉ុណ្ណោះ។

ការចោទប្រកាន់អំពីការផ្សាយព័ត៌មានមិនពិតទៅលើជនសង្ស័យ ៤នាក់ គឺធ្វើឡើងដោយផ្អែកទៅលើឧប្បត្តិហេតុដែលបានកើតឡើងកាលពី ៤ ខែ កន្លងមកហើយគឺ ថ្ងៃទី៤ ខែមករា ឆ្នាំ២០១០ ពុំមានអ្វីដែលជាធាតុផ្សំត្រូវធ្វើបន្ទាន់ឡើយ។ គេនៅមិនទាន់ដឹងច្បាស់ថា ហេតុអ្វីបានជាព្រះរាជអាជ្ញាមិនធ្វើការកោះហៅ និងសាកសួរជនសង្ស័យទាំង ៤ នាក់នោះ ដោយយោងតាមមាត្រា១១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ដែលការធ្វើបែបនេះ អាចផ្តល់ឱកាសឱ្យព្រះរាជអាជ្ញាបានដឹងអំពីភាពខុសគ្នាពាក់ព័ន្ធនឹងព័ត៌មានផ្ទាល់ខ្លួនរបស់ជនសង្ស័យយ៉ាងតិចក៏ម្នាក់ដែរ និងអាចប្រមូលព័ត៌មាន

[៤] មាត្រា ១២៤ ទាក់ទងនឹងមាត្រា ៤៣ និង៤៥ (ព្រហ្មទណ្ឌកិតស្រាល) នៃក្រមនិតិវិធីព្រហ្មទណ្ឌ។

បានច្រើនលើសពីអ្វីដែលមានក្នុងរបាយការណ៍របស់នគរបាលថែមទៀតផង។ ទាំងនគរបាលយុត្តិធម៌ និងព្រះរាជអាជ្ញាពុំបានបង្ហាញនូវចេតនាណាមួយក្នុងការទាក់ទងជាផ្លូវការជាមួយជនសង្ស័យឡើយ នៅក្នុងដំណាក់កាលស៊ើបអង្កេតបឋមរបស់ខ្លួន។

## ការស៊ើបសួរដោយចៅក្រមស៊ើបសួរ និងការឃុំឃាំងនៅនគរបាល

បន្ទាប់ពីទទួលបានដីការបញ្ជូនរឿងអោយស៊ើបសួរចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១០ ពីព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ នៅតុលាការខេត្តតាកែវ លោក បួង ឆ្លាម បានដាក់ឈ្មោះជនសង្ស័យទាំង ៤ នាក់ ដែលមានឈ្មោះរួចមកហើយក្រោមការស៊ើបអង្កេតព្រហ្មទណ្ឌជាផ្លូវការ[៥] ចោទពីបទផ្សាយព័ត៌មានមិនពិតពាក់ព័ន្ធជាមួយនឹងការចែកផ្សាយខិតប័ណ្ណចំនួន ៥៨៧ សន្លឹក នៅថ្ងៃទី៤ ខែមករា ឆ្នាំ២០១០ នៅក្រុងដូនកែវ ខេត្តតាកែវ។ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១០ គាត់បានចេញនូវ"ដីការបង្គាប់អោយនាំខ្លួន" ដោយយោងតាមមាត្រា ១៨៩ និង ១៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឱ្យនាំខ្លួនជនសង្ស័យទាំង ៤ នាក់ រួមទាំងឈ្មោះ"*លាង សុខលី ហៅ ជឿន*"ផងដែរ។

មុននឹងចេញដីកាបង្គាប់អោយនាំខ្លួននេះ ចៅក្រមស៊ើបសួរ មិនបានកោះហៅជនសង្ស័យមកសាកសួរទេ[៦]។ ប៉ុន្តែចៅក្រមស៊ើបអង្កេតបានអនុញ្ញាតឱ្យនគរបាលចាប់ខ្លួនជនសង្ស័យ ដោយពុំមានការជូនដំណឹងជាមុនឡើយ។ ដូច្នេះ នៅពេលដែលនគរបាលមកពីនាយកដ្ឋានសន្តិសុខផ្ទៃក្នុងចាប់ខ្លួន ឈ្មោះ លាង សុខជឿន នៅឯផ្ទះរបស់គាត់នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១០ គាត់ពិតជាពុំបានដឹងនូវបទល្មើសដែលតុលាការបានចោទប្រកាន់គាត់ទាល់តែសោះ។

យោងតាមមាត្រា ១៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ " ដីការបង្គាប់អោយនាំខ្លួន" គឺជាការតម្រូវឱ្យមន្ត្រីនគរបាលយុត្តិធម៌នាំខ្លួនជនណាម្នាក់ដែលមានសំអាងច្បាស់លាស់ទៅចំពោះមុខចៅក្រមស៊ើបសួរ "ជាបន្ទាន់"។ ប្រសិនបើ "*មូលហេតុនៃកាលៈទេសៈ*" បុគ្គលដែលពាក់ព័ន្ធមិនអាចត្រូវនាំទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរក្រោយពេលចាប់ខ្លួនបានទេ បុគ្គលនោះត្រូវតែនាំខ្លួនទៅបង្ហាញខ្លួនយ៉ាងយូរបំផុតថ្ងៃបន្ទាប់ បើមិនដូច្នេះទេត្រូវដោះលែង។ ប៉ុន្តែ ក្នុងករណីនេះ នាយកដ្ឋានសន្តិសុខផ្ទៃក្នុងបានពន្យាពេលរហូតដល់ជិត ៣ សប្តាហ៍ ក្នុងការអនុវត្តនីនូវ " *ដីកាបង្គាប់អោយនាំខ្លួន* " ចំពោះលោកលាង សុខជឿន នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១០ ដែលត្រូវជាថ្ងៃសៅរ៍ទៀត។ ការពន្យាពេលបែបនេះបានធ្វើឱ្យ " ស្ថានភាព " មិនអាចនាំខ្លួនជនសង្ស័យទៅចំពោះមុខចៅក្រមស៊ើបសួរ "ភ្លាមៗ"បានឡើយអាស្រ័យដោយថ្ងៃសៅរ៍ជាថ្ងៃដែលតុលាការខេត្តតាកែវសម្រាកពីការងារ។

---

[៥] មាត្រា ១២៦ (១) នៃក្រមនិតិវិធីព្រហ្មទណ្ឌ។

[៦] មាត្រា ១៨៦ នៃ ក្រមនិតិវិធីព្រហ្មទណ្ឌ។

ការអនុវត្តដីកាអោយនាំខ្លួននោះ គួរត្រូវបានធ្វើឡើងនៅថ្ងៃធ្វើការដើម្បីធានាឱ្យមានការបញ្ជូនជនសង្ស័យភ្លាមៗទៅចំពោះមុខចៅក្រមស៊ើបសួរខេត្តតាកែវ។ ប៉ុន្តែ ផ្ទុយទៅវិញ លោក លាង សុខជឿន បែរជាត្រូវបានបញ្ជូនទៅអគ្គនាយកដ្ឋាននគរបាលជាតិនៅភ្នំពេញ ហើយត្រូវបានឃុំខ្លួនដោយផ្តាច់ការទាក់ទងអស់រយៈពេល ៣៣ ម៉ោងចាប់តាំងពីពេលដែលគាត់ត្រូវបានចាប់ខ្លួននៅម៉ោង ៦ និង១៥នាទីព្រឹកថ្ងៃសៅរ៍ ទី២៩ ខែឧសភា ឆ្នាំ២០១០ រហូតដល់ម៉ោង ៣ និង៤០នាទី រសៀលនាថ្ងៃអាទិត្យ ទី៣០ ខែឧសភា ឆ្នាំ២០១០។

ទោះបីជាមានការស្នើសុំពីសំណាក់គ្រួសារ និងមេធាវីរបស់គាត់ម្តងហើយម្តងទៀតដើម្បីជួបក៏ដោយក៏នគរបាលនៅតែបដិសេធមិនព្រមឱ្យជួប។ ក្នុងកំឡុងពេល ៣៣ ម៉ោងនៅក្នុងការឃុំឃាំងរបស់នគរបាល លោក លាង សុខ ជឿន ត្រូវបានសួរចម្លើយដោយវិធីសាស្ត្រ និងយុទ្ធសាស្ត្រនានាដែលប្តូរផ្លាស់រវាងការគំរាម និងការលួងលោមក្នុងគោលបំណងដើម្បីជម្រិតយកចម្លើយពាក់ព័ន្ធនឹងការចោទប្រកាន់ដែលមានលក្ខណៈមិនច្បាស់លាស់នៅឡើយចំពោះគាត់។

នៅក្នុងភារកិច្ចអនុវត្តច្បាប់ នគរបាលបាលបានអនុវត្តដោយមានការខ្វះចន្លោះក្នុងការជូនដំណឹងទៅលោក **លាង សុខជឿន** អំពីមូលហេតុនៃការចាប់ខ្លួនរបស់គាត់ ព្រមទាំងការបញ្ជូនទៅឃុំខ្លួននៅមន្ទីរឃុំឃាំងរបស់នគរបាលផង និងសិទ្ធិរបស់គាត់ក្នុងការជួបមេធាវី ឬ ជនណាម្នាក់ដែលគាត់ចង់ជួបក្រោយពីត្រូវបានឃុំឃាំងអស់រយៈពេល ២៤ ម៉ោង [៧]។ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ មន្ត្រីនគរបាលមានកាតព្វកិច្ចក្នុងការធ្វើកំណត់ហេតុឃុំឃាំង ដែលត្រូវដាក់បញ្ចូលនូវ *"អត្តសញ្ញាណនៃជនដែលជាប់ឃុំឃាំង"*[៨] នគរបាលយុត្តិធម៌គួរត្រូវបានកត់ត្រានូវភាពខុសគ្នារវាងសាវតាររបស់លោក លាង សុខជឿន និងជនដែលបានកំណត់អត្តសញ្ញាណនៅក្នុង " *ដីការបង្គាប់អោយនាំខ្លួន*" *ឈ្មោះ លាង សុខលី ហៅ ជឿន ជនជាតិវៀតណាមរស់នៅខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ*" ។ ប៉ុន្តែ នគរបាលនៅតែ ពុំបានជូនដំណឹងទៅចៅក្រមស៊ើបសួរអំពីភាពខុសគ្នាយ៉ាងខ្លាំងនេះទៀត ឬ ពិចារណាក្នុងការដោះលែង លោក លាង សុខជឿន រងចាំការស៊ើបអង្កេតបន្ថែមទៀតឡើយ។

[៧] មាត្រា ៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

[៨] មាត្រា ៩៧ (២) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## ការឃុំខ្លួនបណ្តោះអាសន្ន

នៅថ្ងៃសៅរ៍ ទី៣០ ខែឧសភា ឆ្នាំ២០១០ វេលាម៉ោង ៣ និង៤០នាទីរសៀល លោក លាង សុខជឿន បានបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបអង្កេតក្នុងតុលាការខេត្តតាកែវ ដោយមន្ត្រីនគរបាលមកពីនាយកដ្ឋានសន្តិសុខផ្ទៃក្នុង[៩] ។ នេះគឺជាលើកដំបូងដែលមេធាវី និងគ្រួសាររបស់គាត់អាចជួបមុខ លោក លាង សុខជឿនបាន ។

ចៅក្រមស៊ើបសួរ បានស្តីបន្ទោសមន្ត្រីនគរបាលដែលធ្វើរបាយការណ៍ ដោយបានស្លៀកពាក់សម្លៀកបំពាក់ស៊ីវិល និងមិនបានធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរ ប៉ុន្តែ ក៏បានឈប់ទៅវិញជាការចាត់នូវវិធានការតាមនិតិវិធី ។

នៅក្នុងសវនាការពាក់ព័ន្ធនឹងបញ្ហាការឃុំខ្លួនបណ្តោះអាសន្ន មេធាវីរបស់ លោក លាង សុខជឿន បានលើកឡើងនូវបញ្ហាមួយចំនួនពាក់ព័ន្ធនឹងភាពមិនត្រឹមត្រូវនៃ "ដីការបង្គាប់អោយនាំខ្លួន" ។ សំអាងទៅលើបញ្ហាធ្ងន់ធ្ងរពាក់ព័ន្ធនឹងអត្តសញ្ញាណរបស់ជនសង្ស័យ ដែលមាននៅក្នុងបញ្ជូផ្លូវការដែលបង្ហាញនូវភាពខុសគ្នាយ៉ាងខ្លាំងអំពីបញ្ហាឈ្មោះ សញ្ជាតិ និងអាសយដ្ឋានរបស់កូនក្តី ហើយពេលនោះមេធាវីបានស្នើសុំឱ្យដោះលែង លោក លាង សុខជឿនជាបន្ទាន់ ។

មេធាវីក៏បានទាមទារផងដែរ ដោយលើកឡើងថា ទោះបីជាមានបញ្ហាអត្តសញ្ញាណក៏ដោយក៏គ្មានមូលដ្ឋានច្បាប់ណាដែលអាចបង្វែរពីគោលការណ៍សំខាន់ចែងនៅក្នុងក្រមនិតិវិធីព្រហ្មទណ្ឌ " ថា *ជនដែលត្រូវចោទប្រកាន់ត្រូវតែមានសេរីភាព* "[១០] ។ គាត់បានបញ្ជាក់ថា កូនក្តីរបស់គាត់ត្រូវបានចោទប្រកាន់ពីបទមជ្ឈិមពុំមែនជាបទឧក្រិដ្ឋទេ ។ គាត់ក៏បានលើកឡើងផងដែរថា ការឃុំខ្លួនបណ្តោះអាសន្ននេះ ពុំបានអនុវត្តតាមមូលដ្ឋានដែលមានចែងនៅក្នុងច្បាប់ទេ ។[១១] ដោយសំអាងទៅលើអាសយដ្ឋានអចិន្ត្រៃយ៍របស់លោក លាង សុខជឿន ការងារជាប្រចាំ និងទំនាក់ទំនងគ្រួសារប្រកបដោយស្ថេរភាពទាំងនេះ អាចធានាថា គាត់អាចមានមុខនៅតុលាការគ្រប់ពេលឱ្យតែតុលាការតម្រូវឱ្យគាត់ចូលខ្លួន ។

ទោះបីជាបែបនេះក្តី ចៅក្រមស៊ើបសួរនៅតែបញ្ជាឱ្យនាំខ្លួន លោក លាង សុខជឿន ទៅឃុំឃាំងនៅពន្ធនាគារខេត្ត ។ គាត់បានបញ្ជាក់ពីការបារម្ភថា ជនសង្ស័យ (១) អាចប្រព្រឹត្តបទល្មើសបែបនេះម្តងទៀត[១២] (២) អាចយាយីរំខានដល់សាក្សី ជនរងគ្រោះ ឬ ឃុបឃិតជាមួយជនសមគំនិត[១៣] (៣) ជនសង្ស័យអាចបាត់ខ្លួន[១៤] ឬ (៤) អាចបង្ក

---

[៩] មាត្រា ១៩៣ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ។

[១០] មាត្រា ២០៣ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ។

[១១] មាត្រា ២០៥ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ។

[១២] មាត្រា ២០៥ លេខ ១ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ។

[១៣] មាត្រា ២០៥ លេខ ២ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ។

ការគំរាមកំហែងដល់សណ្តាប់ធ្នាប់សង្គម[១៥]។ មូលហេតុទាំងនេះត្រូវបានតុលាការប្រើប្រាស់ដដែលៗ នៅក្នុងករណីនយោបាយ ដើម្បីធ្វើយ៉ាងណាឱ្យជនដែលជាប់ពាក់ព័ន្ធគេចមិនផុតពីការឃុំខ្លួនរហូតដល់អង្គនិតិប្រតិបត្តិដាក់បទបញ្ជាថាត្រូវធ្វើយ៉ាងណាចំពោះករណីនេះ។ ក្រោយមក មេធាវីរបស់គាត់ ក៏ដាក់សំណើជាលាយលក្សអក្សរស្នើសុំដោះលែងកូនក្តីឱ្យនៅក្រៅឃុំក៏នៅតែត្រូវបានតុលាការបដិសេធដោយសំអាងលើមូលហេតុដដែលខាងលើ។

## ការចោទប្រកាន់ពីបទផ្សាយព័ត៌មានមិនពិត

យោងតាមដីការបញ្ជូនរឿងអោយស៊ើបសួរ ដោយអយ្យការអមតុលាការ បុគ្គលដែលមានឈ្មោះថា "*លោក លាង សុខលី ហៅ ជឿន*" ត្រូវបានចោទពីបទ ផ្សាយព័ត៌មានមិនពិត[១៦] បញ្ញត្តិ ដែលត្រូវអាជ្ញាធររដ្ឋាភិបាលបានប្រើប្រាស់ដដែលៗជាច្រើនដងមកហើយដើម្បីប្តឹងពួកអ្នកជំទាស់រួមមានអ្នកសារព័ត៌មាន និពន្ធនាយក និងសកម្មជននយោបាយជាដើម[១៧]។

បទល្មើសផ្សាយព័ត៌មានមិនពិតបានចែងថា " ជនណាម្នាក់ដែលទទួលខុសត្រូវក្នុងការបោះពុម្ពផ្សាយ ឬ វិធីទំនាក់ទំនងផ្សេងៗទៀត ដែលសម្រេចក្នុងការផ្សាយ ចែកផ្សាយ ឬ ផ្សាយព័ត៌មានឡើងវិញដែលជាព័ត៌មានមិនពិតប្រឌិត ព័ត៌មានក្លែងក្លាយ ឬ ពាក់ព័ន្ធដោយមិនពិតដល់ជនទី៣ ណាម្នាក់ ហើយធ្វើក្នុងចេតនាទុច្ចរិត ឬ ក្នុងចេតនាព្យាបាទ ហើយអំពើនោះបណ្តាលឱ្យមានការរំខានដល់សន្តិសុខសាធារណៈ "ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ ខែ ដល់ ៣ ឆ្នាំ ពិន័យជាប្រាក់ ឬ ទាំងពីរ។ ការចោទប្រកាន់នៅក្នុងករណីនេះ គឺពាក់ព័ន្ធទៅនឹងការការចែកផ្សាយខិតប័ណ្ណចំនួន ៥៨៧ សន្លឹក ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី៤ ខែមករា ឆ្នាំ២០១០ នៅក្រុងដូនកែវ ខេត្តតាកែវ។

ក្រៅពីបញ្ហាដែលបង្កើតឡើងដល់ការពាក់ព័ន្ធចំពោះជនសង្ស័យនីមួយៗ បញ្ហាប្រឈមមួយដ៏ធំសំរាប់ការចោទប្រកាន់នោះនឹងបង្ហាញថា តើខិតប័ណ្ណនោះមានសរសេរនូវ "*ព័ត៌មានមិនពិត ប្រឌិត ឬ ក្លែងបន្លំឬទេ*" ដោយហេតុថាព័ត៌មានទាំងនោះសុទ្ធតែជាខ្លឹមសារនយោបាយ ការបញ្ចេញមតិយោបល់។ លើសពីនេះទៅទៀត ទស្សនៈដែលលើកឡើងអំពីការរំខានដល់សាធារណៈ នោះតម្រូវឱ្យព្រះរាជអាជ្ញាបញ្ជាក់ថា ការចែកផ្សាយខិតប័ណ្ណចំនួន ៥៨៧ សន្លឹកនៅក្នុងឧប្បត្តិហេតុមួយនោះ ថាតើវានាំឱ្យមានចលាចលដ៏ធំមួយរញ្ជួយដល់សន្តិសុខ និងសណ្តាប់ធ្នាប់ជាមូលដ្ឋានរបស់ជាតិទាំងមូលដែរឬទេ។

---

[១៤] មាត្រា ២០៥ លេខ ៤ នៃក្រមនិតិវិធីព្រហ្មទណ្ឌ។

[១៥] មាត្រា ២០៥ លេខ ៤ នៃក្រមនិតិវិធីព្រហ្មទណ្ឌ។

[១៦] មាត្រា ៦២ នៃបញ្ញត្តិពាក់ព័ន្ធនឹងតុលាការ និងក្រមព្រហ្មទណ្ឌ និង និតិវិធីអនុវត្តនៅកម្ពុជាក្នុងសម័យអន្តរកាល (ហៅថា ច្បាប់ព្រហ្មទណ្ឌអ៊ុនតាក់)

[១៧] សូមអានរបាយការណ៍ របាយការណ៍សិទ្ធិមនុស្សនៅកម្ពុជាឆ្នាំ២០០៩: ថ្ងៃទី១១ ខែមិនា ឆ្នាំ២០១០ – ក្រសួងការបរទេសសហរដ្ឋអាមេរិក។ http://www.state.gov/g/drl/rls/hrrp/2009/eap/135988.htm

# សេចក្តីសន្និដ្ឋាន

ការស៊ើបអង្កេត ការចាប់ និងឃុំខ្លួន លោក លាង សុខជឿន ពីបទព្រហ្មទណ្ឌ បានបង្ហាញឱ្យឃើញនូវការរំលោភលើនិតិវិធីច្បាប់កម្ពុជាយ៉ាងធ្ងន់ធ្ងរជាច្រើនចំណុច។ បញ្ញត្តិទាំងនេះ មានគោលបំណងការពារពលរដ្ឋកម្ពុជាពីការដកហូតសេរីភាពដោយខុសច្បាប់ និងតាមអំពើចិត្ត។

វិធានការដ៏មានប្រសិទ្ធិភាពតែមួយគត់ក្នុងការដោះស្រាយបញ្ហាការប្រព្រឹត្តិតាមអំពើចិត្តនៅក្នុងការស៊ើបអង្កេតបទព្រហ្មទណ្ឌទាំងមូល និងការដកហូតសេរីភាពលោក លាង សុខជឿន គឺការការដោះលែងជាបន្ទាន់ និងគ្មានលក្ខខណ្ឌពីការឃុំឃាំងបណ្តោះអាសន្ន។ ជាងនេះទៅទៀត ត្រូវធ្វើការស៊ើបអង្កេតអំពីការឃុំខ្លួនដោយផ្តាច់ការទំនាក់ទំនងរយៈពេល ៣៣ ម៉ោងនៅឯអគ្គនាយកដ្ឋាននគរបាលជាតិ ដោយមន្ត្រីនគរបាលមកពីនាយកដ្ឋានសន្តិសុខផ្ទៃក្នុង។

**ព័ត៌មានបន្ថែមសូមទាក់ទង:**

| | | |
|---|---|---|
| លោកស្រី វេជ្ជ. ពុង ឈីវកេក ប្រធានអង្គការលីកាដូ | ទូរស័ព្ទលេខ | ០១២ ៨០២ ៦៥០ |
| លោក អំ សំអាត អ្នកគ្រប់គ្រងបច្ចេកទេសឃ្លាំមើលការរំលោភសិទ្ធិមនុស្ស | ទូរស័ព្ទលេខ | ០១២ ៣២៧ ៧៧០ |
| កញ្ញា ណាលី ពីឡូក នាយិកាអង្គការលីកាដូ | ទូរស័ព្ទលេខ | ១០២ ៨០៣ ៦៥០ |